ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិសម្រាប់ក្រុមបុរសស្រឡាញ់បុរស

## ថ្ងៃទី០៥ ខែមិនា ឆ្នាំ២០១២

## ចាប់ពីម៉ោង: ១៤:០០ រហូតដល់ម៉ោង ១៧:០០ រសៀល

**១.គោលបំណង**

-ពិភាក្សាការងារដើម្បីផលិតនូវរបាយការណ៍សមិទ្ធិផលប្រចាំឆ្នាំ២០១១នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស នៅកម្ពុជា។

-ពិនិត្យមើលផែនការសកម្មភាពសំរាប់ឆ្នាំ ២០១២

**២.កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន**

-កាលបរិច្ឆេទៈថ្ងៃទី ០៥ ខែមិនា ឆ្នាំ ២០១២

-ទីកន្លែងៈនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-វត្តមានៈ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ RHAC FHI360 PSI BC N MHSS MSIC and KANHNHA

-អវត្តមានៈ KHANA UNAIDS UNESCO MHC KDFO Pact Cambodia and CSSD

**៣.វិធីសាស្ត្រ**

-ជួបប្រជុំជាមួយសមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិក្រុមបុរសស្រឡាញ់បុរស

**៤.លទ្ធផល**

កាលពីថ្ងៃទី០៥ ខែមិនា ឆ្នាំ២០១២ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានរៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមការងារបច្ចេកទេសថ្នាក់ជាតិសម្រាប់ក្រុមបុរសស្រឡាញ់បុរស ស្តីពីការរៀបចំផលិតនូវរបាយការណ៍សមិទ្ធិផលប្រចាំឆ្នាំ២០១១ នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរសនៅកម្ពុជា និងពិនិត្យមើលផែនការសកម្មភាពសំរាប់ឆ្នាំ ២០១២។ អញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ដោយឯកឧត្តម វេជ្ជ. តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ជាកិច្ចចាប់ផ្តើម ឯកឧត្តម បានស្វាគមន៍ និងអរគុណយ៉ាងជ្រាវជ្រៅចំពោះវត្តមាន សមាជិកតំណាងឱ្យក្រុមការងារបច្ចេកទេសថ្នាក់ជាតិ បុរសស្រឡាញ់បុរស ដែលជាសកម្មជន ក្នុងការឆ្លើយតប ទៅនឹងបទអន្តរាគមន៍បង្ការការរីករាលដាលមេរោគ និងជំងឺអេដស៍។ ប្រធាន

បទសំខាន់ដែលលើកយកមកពិភាក្សាថ្ងៃនេះ គឺការផលិតនូវរបាយការណ៍សមិទ្ធិផលប្រចាំឆ្នាំ២០១១នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស នៅកម្ពុជា ពិនិត្យមើលផែនការសកម្មភាពសំរាប់ឆ្នាំ ២០១២ និងបញ្ហាផ្សេងៗទៀត ។ អង្គប្រជុំបានពិភាក្សាលំអិតទៅតាមចំនុចនីមួយៗនៃប្រធានបទ និងបានសំរេចលទ្ធផលដូចខាងក្រោម

ការផលិតនូវរបាយការណ៍ដោយរៀបចំៈ

- ការងារលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស
- ការសំរបសំរួលថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- វគ្គបណ្តុះបណ្តាល និងការតស៊ូមតិ
- ការគាំទ្រ និងព្យាបាល ( គ្លីនីក សុខភាពគ្រួសារ ឈូកស RHAC MSIC MEC )

គ្រប់អង្គការដៃគូ ផ្តល់ផែនការសកម្មភាព និងប្រតិបត្តិសំរាប់ឆ្នាំ២០១២ មកលេខាធិការដ្ឋានមុនថ្ងៃទិ០៩ មិនា ២០១២ ។

រៀបចំប្រជុំប្រចាំត្រីមាសទីមួយនៅថ្ងៃទី ២២ ខែមិនា ឆ្នាំ២០១២ ដែលមានកម្មវិធីៈ

- ការបង្ហាញផែនការសកម្មភាព និងផែនការប្រតិបត្តិរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស
- ការបង្ហាញនូវរបាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស
- បញ្ហាផ្សេងៗ

ជាទីបញ្ចប់ ឯកឧត្តម អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងអំណរគុណ និងកោតសរសើរចំពោះ ការខិតខំប្រឹងប្រែងរបស់សមាជិក ដែលជាសកម្មជនបាន សហការគ្នាល្អធ្វើឱ្យការងារឆ្លើយតបទៅការ ទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ទទួលលទ្ធផល គួរឱ្យកោតសរសើរទោះបីមានជួបបញ្ហា មួយចំនួនក៏ដោយ ។

ភ្នំពេញថ្ងៃទី០៦ ខែមិនា ឆ្នាំ ២០១២

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យ | |
|---|---|---|
| អគ្គលេខាធិការ | ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ | អ្នកធ្វើរបាយការណ៍ |
| [signature] | [signature] យស់ ... | [signature] |